ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមករា ឆ្នាំ២០២០

នៅក្នុងខែមករា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន:

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតជូនលោកជំទាវ Felicidada de Sousa Guterres ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ចូលជួបសម្តែងការគួរសម និងជម្រាបលា

-អនុញ្ញាតជូនឯកឧត្តម Muhannad Faruk Khan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការបរទេសនៃរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អនុញ្ញាតជូនឯកឧត្តម IMAMURA Masahiro ប្រធានសម្ព័ន្ធមិត្តភាពសភាជប៉ុន-កម្ពុជា និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អនុញ្ញាតជូនឯកឧត្តម W.Patriick Murphy ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ

-អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារ១៦ ខែដំបូង និងទិសដៅការងារឆ្នាំ២០២០របស់ឧត្តមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នៅសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកួតកីឡាវាយកូនគោល ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីលានវាយកូនគោលវឌ្ឍនៈហ្គោលរីស៊ត រាជធានីភ្នំពេញ

-អញ្ជើញជាគណៈអធិបតីក្នុងពិធីមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនា-បតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៩ច្បាប់ ។

**១.២-ឯកឧត្តម ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញចូលរួមពិធីមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន៥៤ច្បាប់ ។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាថ្នាក់ខេត្តស្តីពី ការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព នៅខេត្តមណ្ឌលគិរី

-អញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី និងចូលរួមជាកិត្តិយសក្នុងពិធីមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤១ ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជា-ណាចក្រកម្ពុជា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមកុមារនៃក្តីសង្ឃឹមកម្ពុជា ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំរកាខ្ពស់ ស្រុកស្អាង និងសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-អញ្ជើញចុះសួរសុខទុក្ខ និងចែកសម្ភារសិក្សាមួយចំនួនដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ដែលរស់នៅតំបន់ដាច់ស្រយាល នៅសាលាបឋមសិក្សាសាមុត្រលើ ឃុំសេដា ស្រុកលំផាត់ ខេត្តរតនគិរី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៦ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំចំនួន០២លើក ដែលមានរបៀបវារៈដូចខាងក្រោមៈ

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពី ច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនហ្គ្រីន សឹស្តែនណេប៊ិល វេនឈ័រ (ខេមបូឌា) ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ អានុភាព២០ មេហ្គាវ៉ាត់ នៅខេត្តស្វាយរៀង

៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ាយ ផៅវ័រ ស៊ីបផ្លាយ ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តបន្ទាយមានជ័យ

៤-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ាយសិន អេនើជី ( ខេមបូឌា )

បាត់ដំបង ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ អានុភាព៦០ មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង

៥-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្នេថេក អ៊ីនហ្វីនីត ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់

៦-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ធីអេសប៊ីគី សេកុង ផៅវ័រ អ៊ែនមីនើរ៉ល ខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៧-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនសេកុង សឺមម័ល ផៅវ័រ ផ្ទេនខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៨-ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១៩

៩-ពិនិត្យ និងសម្រេចអំពីគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២០

១០-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៤។

**៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់ការអនុវត្តបទប្បញ្ញត្តិ នៃអនុសញ្ញាសហប្រជាជាតិស្ដីពី ច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋា-ភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនហ្គ្រីន សឹស្តែនណេប៊ិល វេនឈ័រ (ខេមបូឌា) ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ អានុភាព ២០ មេហ្គាវ៉ាត់ នៅខេត្តស្វាយរៀង

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិ-បាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ាយ ផៅវ័រ សឹបផ្ទាយ ឯ.ក សម្រាប់ គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព៣០មេហ្គាវ៉ាត់នៅខេត្តបន្ទាយមានជ័យ

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិ-បាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ាយសិន អេនើជី (ខេមបូឌា) បាត់ដំបង ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យអានុភាព៦០ មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិ-បាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្មេថេក អ៊ីនហ្វីនីត ឯ.ក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យអានុភាព៣០មេហ្គាវ៉ាត់នៅខេត្តពោធិ៍សាត់

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិ-បាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនធីអេសប៊ីភី សេកុង ផៅវ័រ អ៊ែនមីនើរ៉ល ខម-ភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិ-បាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនសេកុង សឺមម័ល ផៅវ័រ ផ្លេនខមភេនី លីមីធីត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

## ៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែមករានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

### ៤.១-មុខងារនីតិកម្ម

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរ-គណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់ ។

**៤.២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីស្ថានភាពជាក់ស្តែងរបស់ឃុំ និងពិភាក្សាដោះស្រាយទំនាស់ដីធ្លីជូនប្រជាពលរដ្ឋ នៅឃុំកំពង់ឫស្សី ស្រុកពោធិរៀង ខេត្តព្រៃវែង ។

**៤.៣-មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៧ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០២ករណី កំពុងពិនិត្យសិក្សាចំនួន០៧ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន០៨ករណី

-បានរៀបចំវេទិកាសាធារណៈថ្នាក់ខេត្តស្តីពី ការពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកា និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព នៅខេត្តមណ្ឌលគិរី

-អញ្ជើញចុះសួរសុខទុក្ខ និងចូលរួមរំលែកទុក្ខ ព្រមទាំងឧបត្ថម្ភថវិកាដល់ក្រុមគ្រួសារកម្មករដែលជួបឧបទ្ទវហេតុបាក់រលំអគារ៧ជាន់ នៅខេត្តកែប

-អញ្ជើញធ្វើបទបង្ហាញដល់សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដាចំនួន៥៣នាក់មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

-អញ្ជើញជាគណៈអធិបតីក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅបន្តឆ្នាំ២០២០ របស់គណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍

-អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សា និងសម្រេចលើមូលបទ និងប្រធានបទនៃកិច្ចប្រជុំភាពជាដៃគូអាស៊ី-អឺរ៉ុបលើកទី១១ (Asia Europe Pariamentary Partnership Meeting)

-អញ្ជើញចូលរួមស្តាប់បទបង្ហាញរបស់វិទ្យាស្ថានសភាកម្ពុជាស្តីពី ទិដ្ឋភាពទូទៅលើការបែងចែកថវិកា និងទូទាត់ថវិកាថ្នាក់ក្រោមជាតិសម្រាប់ការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងចំនួន១២៣លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា

តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦៧លើក ។

**៥-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាទៅទស្សនកិច្ចការងារ និងពិភាក្សាអំពីការអភិវឌ្ឍលើវិស័យវេជ្ជសាស្ត្រសុខាភិបាល និងពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាព និងទំនាក់ទំនងសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី នៅទីក្រុងហ្គុងជូ ប្រទេសកូរ៉េខាងត្បូង

-ឯកឧត្តម **ខៀវ មុត** អញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (APPF) លើកទី២៨ នៅទីក្រុងកង់ប៉េរ៉ា ប្រទេសអូស្ត្រាលី ។/

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ